# គ្រូ និង សិស្ស (សម្រង់ចាកសៀវភៅរឿងព្រេងខ្មែរ ភាគទី១)

មានរឿងមួយដំណាលថា មានភិក្ខុមួយអង្គគង់នៅវត្ត មានកូនសិស្សតែម្នាក់ឈ្មោះ អាផ្លូញ ។ អាផ្លូញជាក្មេងខិលណាស់ ឯគ្រូល្ងង់ណាស់ ឆោតច្រើន គ្មានឧបាសក ឧបាសិកាណារាប់អានយកចង្ហាន់ស្ងាបារីទៅប្រគេនឬនិមន្តលោកនោះមកឆាន់ផ្ទះដល់ម្តងឡើយ លោកនោះក្រលំបាកពន់ពេក តែលោកមានដំរីមួយ ។ ថ្ងៃមួយលោកនោះពិចារណាថា "សព្វថ្ងៃនេះគ្មានឧបាសក ឧបាសិកាគេប្រគល់វត្ថុអ្វីឆាន់សោះ បើដូច្នោះគួរអញទិញវត្ថុផ្សេងៗយកមកទុកឆាន់កុំឲ្យលំបាក" ។ គិតដូច្នោះហើយក៏ប្រាប់កូនសិស្សថា "អាផ្លូញឯងចាប់ដំរីមក ហើយឯងទៅផ្សារនឹងអញ រកទិញវត្ថុផ្សេងៗយកមកទុកឆាន់" ។ កូនសិស្សក៏ទៅចាប់ដំរីមក



គ្រូនិងសិស្សក៏ឡើងជិះដំរីទៅផ្សារ ។ លុះទៅដល់ផ្សារគ្រូក៏ប្រាប់កូនសិស្សឱ្យទៅរកទិញវត្ថុអ្វីដែលទុកបានយូរមិនខូច។ អាផ្លូញជាសិស្សក៏ទិញអំបិលមួយចុង (ទម្ងន់កន្លះហាប ឬ ៣០គីឡូ) គ្រូឃើញក៏សួរថា "ហេតុម្តេចក៏ឯងទិញតែអំបិល មិនទិញត្រីឆ្អើរ ត្រីងៀតផង?" កូនសិស្សទូលថា "អំបិលទុកបានយូរមិនចេះខូច បានជាខ្ញុំព្រះករុណាទិញ" គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម ។ គ្រូឡើងជិះបរដំរីមកវត្តវិញ ឱ្យសិស្សរែកអំបិលដើរតាមពីក្រោយ។



លុះបានពាក់កណ្ដាលផ្លូវគ្រូងាកមើលទៅសិស្ស ឮសូរជង់រែក ង៉ែតង៉ត១ ដូចជាស្រួលក៏សួរថា "អាផ្លូញ អញមើលទៅឯងរែក អំបិលដូចជាស្រួលឬយ៉ាងណា?"

សិស្សទូលថា "ព្រះករុណា! ស្រួលណាស់ហើយស្រាលផង"

លោកគ្រូប្រាប់សិស្សថា "បើអីចឹង ឯងមកជិះដំរីមក ទុកអញរែក អំបិលដើរក្រោយម្ដង!" លោកគ្រូថាហើយក៏ចុះពីលើដំរី ឯសិស្ស ក៏ឡើងជិះដំរីទៅ ។ លោកគ្រូប្រាប់ថា "ឯងបរដំរីទៅចាំអញនៅ ម្ងប់ឈើខាងមុខ!" តែអាផ្លូញវាបរដំរីទៅដល់ម្ងប់ឈើក៏វាមិន ឈប់ចាំគ្រូ វាបររហូតដល់វត្ត ។

លោកគ្រូរែកអំបិលដើរយូរទៅ កាន់តែធ្ងន់ទៅ ... លោករែកឈប់ៗ បែរមើលទៅសិស្សមិនឃើញក៏គិតថា "នឹងរែកដើរទៅទៀតឃើញថាពុំបានទេ ត្រូវរកកន្លែងលាក់ទុកសិន ចាំពេលក្រោយសឹមអញនាំសិស្សមក យកវិញ!" លោកគ្រូរកកន្លែងលាក់អំបិលលាក់ក្នុងព្រៃ តែចេះតែនឹកភ័យថា "បើលាក់ក្នុងព្រៃ លោតែមាន គេដើរមកចំរកឃើញ គេនឹងយកអំបិលនេះអស់មិនខាន គួរតែរកទីណាដែលកំបាំងភ្នែកអ្នកទាំងពួង គឺមាន តែក្នុងទឹកទើបគេមើលមិនឃើញ" គិតហើយក៏យកអំបិលទៅលាក់ទុកក្នុងទឹកបឹង។

លុះដល់វត្តលោកគ្រូក៏សួរសិស្ស "ហេតុដូចម្ដេចក៏ឯងមិនចាំអញ?"

សិស្សទូលថា "ខ្ញុំព្រះករុណាបរដំរីមកប្រុងចាំលោកគ្រូដែរ តែដំរីវាមិនព្រមចាំសោះ អង្វរដូចម្ដេចក៏វាមិនព្រម វាប្រឹងដើរដល់វត្តទើបឈប់"

គ្រូអន់ប្រាជ្ញាណាស់ ក៏ជឿតាមពាក្យសិស្សគ្រប់ប្រការ។

ព្រឹកឡើងលោកគ្រូនាំកូនសិស្សទៅយកអំបិលវិញ លុះដល់មាត់បឹងលោកប្រាប់ទៅសិស្សថា "អញលាក់អំបិលទុកក្នុងបឹងនេះ អញកាប់ដើមឈូកដោតជាសម្គាល់ ចូរឯងចុះទៅយកមក!"



សិស្សលាន់មាត់ថា "ម៉ែអើយ! វាមិនរលាយអស់ហើយទេឬអី!" អាផ្លូញក៏ចុះទៅយកអំបិល លើកការុងទាំងពីរឡើង ឃើញរលាយអស់គ្មានសល់មួយគ្រាប់ ចំណងដែលចងមាត់ការុងដាច់អស់ ឃើញឯត្រីកញ្ចុះមួយនៅក្នុងការុងនោះ ។ សិស្សទូលលោកគ្រូថា "មានត្រីកញ្ចុះមួយនៅក្នុងការុង វាស៊ីអំបិលអស់ទៅហើយ!"



លោកគ្រូឃើញត្រីខឹងណាស់ ក៏ទះកំផ្លៀងត្រី មុតដៃនឹងធ្មង់ត្រីជាប់ ។ ពិសត្រីចាប់ពើតឈឺខ្លាំងពេក លោកគ្រូថា "ឯងចាប់ត្រី ដកធ្មង់វាចាប់ ព្រោះអញឈឺណាស់!"
សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច ។ លុះដករួចឈាមហូរជាខ្លាំង ពិសត្រីរឹតតែឈឺពើតខ្លាំងឡើង លោកគ្រូនាំកូនសិស្សទៅវត្តវិញយកទាំងការុង និងត្រីកញ្ចុះទៅផង ដល់ទៅវត្តប្រាប់កូនសិស្សថា "អាផ្លូញ ចូរឯងដាំបាយមួយឆ្នាំង អាំងត្រីកញ្ចុះនេះឲ្យឆ្អិនជាចាប់ អញនឹងឆាន់!"

លុះពិសអន់ចាប់ពើត លោកគ្រូក៏សំងំសឹងលក់ទៅ ។ ឯអាផ្លូញក៏ដាំបាយអាំងត្រីឆ្អិនហើយ វាបរិភោគអស់ទុកតែបាយមួយពំនូកនិងឆ្អឹងត្រីក្នុងចានគ្រប តែវាគ្របមិនឲ្យជិតទេ ។ លោកគ្រូភ្ញាក់ឡើងប្រាប់សិស្សថា "ឯងយកបាយ និងត្រីមកឱ្យអញឆាន់!" អាផ្លូញក៏ធ្វើជាកិរិយាដូចជាទៅយកបាយប្រគេនគ្រូ ចេញមកវិញវាស្រែកថា "បាយនិងត្រីរុយស៊ីអស់ទៅហើយ នៅសល់តែមួយពំនូកនិងឆ្អឹងត្រី..." លោកគ្រូជឿឥតសង្ស័យ ដោយឆោតល្ងង់ ក៏ឲ្យរំពាត់ផ្តៅមួយមកសិស្សថា "ចូរឯងវាយរុយ កុំឲ្យវានៅលើកុដិឱ្យសោះ!"

អាផ្លូញជាសិស្សក៏វាយរុយមិនឈប់ ។ គ្រានោះមានរុយទំច្រមុះគ្រូ គ្រូក៏ស្រែកប្រាប់សិស្សឱ្យវាយរុយ។ អាផ្លូញវាយទៅ មិនត្រូវរុយ ត្រូវច្រមុះគ្រូបែកឈាមខ្វាយ វាភ័យណាស់រត់ទៅដល់ផ្ទះ និយាយប្រាប់ឪពុកម្តាយតាមរឿង។ ឪពុកម្តាយប្រាប់កូនឲ្យមកវត្តវិញ កូនប្រកែកមិនព្រមមក ។ លោកគ្រូទៅតាមក៏មិនហ៊ានមកដោយខ្លាចគ្រូវាយ ។

ថ្ងៃមួយលោកគ្រូ តាំងពិធីសូត្រមន្តអាគមស្នេហ៍បន្ទន់ចិត្តសិស្សឲ្យមកវិញ ។ អាផ្លូញជាសិស្សបានដឹងថាគ្រូតាំងពិធីសូត្រមន្តអាគមស្នេហ៍ដូច្នោះ ក៏មកវត្តវិញ ដើម្បីឲ្យគ្រូជឿថាស្នេហ៍ពូកែ ។ លុះទៅដល់វត្ត វាតាំងដើរលបៗចូលទៅឃើញគ្រូកំពុងតែអង្គុយសូត្រមន្តអាគមស្នេហ៍ ក៏សួរលោកថា "លោកគ្រូធ្វើអ្វី?" គ្រូកុហកថា "អញសូត្រមន្តអាគមកំបាំងខ្លួន ព្រោះអញទើបរៀនពីគេ" ហើយលោកគ្រូគិតថា "ស្នេហ៍អញពូកែមែនបានជាសិស្សអញវាមក!"

លុះព្រឹកឡើង សិស្សដាំបាយធ្វើម្ហូបស្រេច ទូលថា "ចង្ហាន់ឆ្អិនហើយ លោកគ្រូ!"

លោកគ្រូថា "បើដូច្នេះឯងលើកយកឲ្យអញឆាន់!"

អាផ្លូញក៏លើកមកប្រគេន ធ្វើជាមើលមិនឃើញ ដាក់ថាសទៅលើក្បាលគ្រូ គ្រូស្រែកថា "អាផ្លូញ! ហេតុម្តេចក៏យកថាសមកដាក់លើក្បាលអញ?!"

សិស្សធ្វើជាភ្ញាក់ ទូលថា "ខ្ញុំព្រះករុណាមើលលោកគ្រូមិនឃើញ!" លោកគ្រូងាកចេញ តែអាផ្ទួញវាដាក់ថាសលើក្បាលគ្រូទៀត ។ លោកគ្រូថា "អាឯងដាក់ថាសលើក្បាលអញទៀតហើយ!"
ឯសិស្សចេះតែតបថា "ខ្ញុំព្រះករុណាសូមទោស ព្រោះមើលមិនឃើញ!"
លោកគ្រូជឿអាផ្ទួញ នឹកថា "អញរៀនស្នេហ៍ ស្នេហ៍ពូកែប្រាកដ! ឥឡូវអញកុហកវាថា តាំងពិធីមន្តអាគមបំបាំងខ្លួនវិញ ក៏ទៅជាពូកែគេមើលមិនឃើញប្រាកដមែន គួរទន្ទេញឲ្យចាំកុំឲ្យភ្លេច! "



ថ្ងៃមួយមានឧបាសកគេនិមនលោកគ្រូទៅឆាន់ឯផ្ទះ ។ អាផ្ទួញទូលថា "បើលោកគ្រូនិមន្តទៅឆាន់ផ្ទះគេ កុំស្លៀកស្បង់ឲ្យចាស់ខូចឥតអំពើ ឃ្លុំតែចីពរបានហើយ គេមើលមិនឃើញទេ ដ្បិតលោកគ្រូចេះមន្តអាគមបំបាំងខ្លួនពូកែណាស់ អ្នកណានឹងមើលឃើញ?"
គ្រូជឿក៏ធ្វើតាមពាក្យសិស្ស ។
លុះព្រឹកឡើងលោកគ្រូប្រាប់សិស្សថា "ឯងតាមអញទៅឆាន់ឯផ្ទះឧបាសក" រួចលោកឃ្លុំតែចីពរមិនស្លៀកស្បង់ ដោយគិតថា "ឃ្លុំតែចីពរបានហើយ ព្រោះមន្តអាគមអញពូកែណាស់ នរណានឹងមើលកេរ្តិ៍ខ្មាសឃើញ?"
លុះទៅដល់គេហដ្ឋានឧបាសក គេនិមន្តលោកឡើងលើផ្ទះហើយគេលើកចង្ហាន់មក ដើម្បីប្រគេនលោកឆាន់ ដោយលោកមិនបានស្លៀកស្បង់ អង្គុយមិនស្រួល ងាកឆ្វេងស្តាំក៏លេចកេរ្តិ៍ខ្មាសកណ្តាលវាល ។ ឧបាសកឃើញដូច្នោះគេក៏នាំគ្នាសើចហ៊ោលាន់ ។ លោកគ្រូ

ពុំទាន់បានធាន់ចង្ហាន់ មានចិត្តខ្មាសគេណាស់ ក៏ចុះពីផ្ទះត្រឡប់មកវត្តវិញ ដេរបន្ទោសសិស្សថា "អាឯងមិនឲ្យអញស្លៀកស្បង់ ឥឡូវអញខ្មាស់គេណាស់!"
អាផ្លូញទូលថា "លោកគ្រូកុំខ្ញាល់នឹងខ្ញុំព្រះករុណា រឿងនេះប្រហែលខុសត្រណមទេដឹង?"
លោកគ្រូសួរថា "ឯងឃើញអញខុសត្រណមដូចម្ដេច?"
អាផ្លូញសួរថា "កាលលោកគ្រូនិមន្តទៅធាន់ផ្ទះឧបាសក និមន្តទៅផ្លូវណា?"
លោកគ្រូប្រាប់ថា "អញកាលទៅចេញផ្លូវកើត"
សិស្សថា "ឱ! ច្បាស់ជាលោកគ្រូខុសត្រណមហើយ ថ្ងៃមុនលោកគ្រូប្រាប់ខ្ញុំព្រះករុណាថា បើរៀនមន្តអាគមទាំងពួងត្រូវឲ្យតមស៊ីផ្លែស្ពឺ សូម្បីតែមុជក្រោមដើមស្ពឺក៏មិនបានដែរ វាសាបមន្តអាគម ឥឡូវលោកមុជក្រោមដើមស្ពឺ សាបអាគមអស់ ហេតុនេះបានជាគេឃើញកេរ្តិ៍ខ្មាស់លោកគ្រូ"
លោកគ្រូបានស្ដាប់ដូច្នោះហើយក៏ថា "ឱ! អាផ្លូញ អញភ្លេចតមបានជាយ៉ាងហ្នឹង ឯងថានោះពិតហើយ!"
លោកគ្រូនោះដោយឆោតល្ងង់ក៏ជឿជាក់អាផ្លូញឥតសង្ស័យ។ តាំងពីនោះមកអាផ្លូញជាសិស្សនៅបម្រើគ្រូដោយសុខសប្បាយតទៅអើយ៕

©KhmerStoryLovers